# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៦១)

**ដាក់ទៅ** : អង្គបុរេជំនុំជម្រះ

**ថ្ងៃដាក់** : ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩

**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ

**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Sep-2019, 14:35
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (D381)**

---

**អ្នកដាក់ឯកសារ:**

លោកស្រី Brenda J. HOLLIS

សហព្រះរាជអាជ្ញាអន្តរជាតិ (បម្រុង)

**ចម្លងជូន:**

លោកស្រី ជា លាង

សហព្រះរាជអាជ្ញាជាតិ

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម Kang Jin BAIK

ចៅក្រម ហួត វុទ្ធី

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៃសំណុំរឿង០០៤**

**សហមេធាវី យឹម ទិត្យ:**

សូ មូហ្សេទ្ធី

Suzana TOMANOVIĆ

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមស្នើអង្គបុរេជំនុំជម្រះ ("អ.ប.ជ" ឬ "អង្គជំនុំជម្រះ") ឲ្យបន្ថែមពេលវេលា និងចំនួនទំព័រដល់សហព្រះរាជអាជ្ញាអន្តរជាតិសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ")[1] ដោយអនុញ្ញាតឲ្យដាក់បណ្តឹងឧទ្ធរណ៍ដែលមានចំនួន ១០០ទំព័រ (មានន័យថា ៧០ទំព័រ បន្ថែមលើចំនួនទំព័រដែលបានកំណត់) ត្រឹមថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលជាការពន្យារពេលវេលា ៣០ថ្ងៃ ចំពោះកាលបរិច្ឆេទកំណត់ជាធរមានបច្ចុប្បន្ន។ ស.ព.អ ក៏ស្វែងរកការអនុញ្ញាតដើម្បីដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនជាភាសាអង់គ្លេសជាមុនផងដែរ ដោយសំណៅបកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន។

២. ស.ព.អ សន្និដ្ឋានថា សំណើនេះនឹងទទួលបានការអនុញ្ញាតដោយសារកត្តាមួយចំនួន ដែលរួមមានភាពស្មុគ្រស្មាញនៃបណ្តឹងឧទ្ធរណ៍ និងសារសំខាន់ខាងផ្លូវច្បាប់ និងអង្គហេតុដែលចោទឡើង ព្រមទាំងគុណភាពនៃសំណៅបកប្រែជាភាសាអង់គ្លេសនៃ ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលយើងអាចរកបាននាពេលនេះ។

៣. ស.ព.អ បានឆ្លើយតបដាច់ដោយឡែកពីគ្នាទៅនឹងសំណើរបស់ យឹម ទិត្យ ទាក់ទងទៅនឹងសំណៅជាភាសាអង់គ្លេសនៃដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ[2] ដោយបានបញ្ជាក់ *ជាអាទិ៍* ថា គាត់មិនជំទាស់ទៅនឹងការផ្អាកកាលបរិច្ឆេទកំណត់សម្រាប់សារណាបណ្តឹងឧទ្ធរណ៍ រហូតទាល់តែសំណៅបកប្រែកដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ឡើងវិញត្រូវបានដាក់ ដោយអង្គភាពបកប្រែភាសានោះទេ។ ទោះបីជាសេចក្តីសម្រេចរបស់ អ.ប.ជ មានផលប៉ះពាល់យ៉ាងដូចម្តេចក៏ដោយលើបញ្ហានៃកាលបរិច្ឆេទកំណត់របស់បណ្តឹងឧទ្ធរណ៍នេះ ក៏ ស.ព.អ ស្នើសុំថា កាលបរិច្ឆេទកំណត់សម្រាប់សារណាបណ្តឹងឧទ្ធរណ៍របស់គាត់គឺមិនមុនថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ឡើយ។

## II. ប្រវត្តិនីតិវិធី

---

[1] ឯកសារ **D381** ដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ, ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ("ដីកាសម្រេចលើកលែងចោទប្រកាន់")។

[2] ឯកសារ **D381/5** & **D382/5** សំណើរបស់ យឹម ទិត្យ សុំឲ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាបន្ទាន់ឲ្យផ្តល់នូវការបកប្រែជាភាសាអង់គ្លេសនៃដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិដែលត្រឹមត្រូវ និង ផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩។

៤. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានចេញដីកាដំណោះស្រាយដាច់ដោយឡែកចំនួនពីរនៅក្នុងសំណុំរឿង ០០៤។ ស.ច.ស.ជ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ជាភាសាខ្មែរ ដែលមានចំនួន ៥៥៨ ទំព័រ[3]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយ មានចំនួន ៤៨២ ទំព័រ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[4] ជាភាសាអង់គ្លេស។

៥. នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ អ.ប.ជ បានផ្តល់ការអនុញ្ញាតដល់ភាគីក្នុងសំណុំរឿង០០៤ ទាំងអស់ ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ខ្លួននៅក្នុងរយៈពេល ១៤ថ្ងៃ បន្ទាប់ពីសំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរត្រូវបានជូនដំណឹង[5]។ សំណៅបកប្រែជាភាសាខ្មែរនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានជូនដំណឹងនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ខណៈដែលសំណៅបកប្រែជាភាសាអង់គ្លេសនៃដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវបានជូនដំណឹងនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩។

៦. នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ស.ព.អ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់[6]។ នៅថ្ងៃ១៧ ខែកញ្ញា ឆ្នាំ២០១៩ យឹម ទិត្យ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់គាត់ ប្រឆាំងទាំងដីកាសម្រេចលើកលែងចោទប្រកាន់ផង និងដីកាបញ្ជូនរឿងទៅជំនុំជម្រះផង[7]។

## III. ច្បាប់ជាធរមាន

[3] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់។

[4] ឯកសារ **D382** ដីកាដំណោះស្រាយ, ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[5] ឯកសារ **D381/3** & **D382/3** សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពន្យារកាលបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤, ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ("សេចក្តីសម្រេចស្តីពីការបន្ថែម"), កថាខណ្ឌ ៧, ផ្នែកសម្រេចសេចក្តី។

[6] ឯកសារ **D381/4** សៀវភៅចុះបណ្តឹងឧទ្ធរណ៍នៃ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (D381), ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩។

[7] ឯកសារ **D382/9** សៀវភៅចុះបណ្តឹងឧទ្ធរណ៍នៃបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។ **D381/7** សៀវភៅចុះបណ្តឹងឧទ្ធរណ៍នៃសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិ លើកលែងការចោទប្រកាន់ យឹម ទិត្យ, ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

៧. វិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង[8] ចែងថា សារណាស្តីពីបណ្តឹងឧទ្ធរណ៍ត្រូវតែដាក់នៅក្នុងរយៈកាល ៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេច ឬដីកាពាក់ព័ន្ធត្រូវបានទទួល។ តាមមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក[9] ("សេចក្តីណែនាំអនុវត្តន៍") ពេលវេលាកំណត់ចាប់ផ្តើមនៅថ្ងៃដំបូងនៃប្រតិទិន បន្ទាប់ពីថ្ងៃធ្វើការនៃការជូនដំណឹងជាភាសាខ្មែរ និងភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក។ មាត្រា ៨.១ នៃ សេចក្តីណែនាំអនុវត្តន៍ និង មាត្រា ៣៩(៤) និងមាត្រា ៧៥(៣) នៃវិធានផ្ទៃក្នុង ចែងថា នៅក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះអាចពន្យារពេលវេលាកំណត់នេះតាមញត្តិរបស់ភាគី។

៨. សេចក្តីណែនាំអនុវត្តន៍តម្រូវថាឯកសារណាក៏ដោយដែលបានដាក់ជូនទៅ អ.ប.ជ មិនត្រូវឲ្យលើស ពី៣០ទំព័រ ជាភាសាអង់គ្លេសនោះទេ ក៏ប៉ុន្តែ អ.ប.ជ អាចបន្ថែមចំនួនទំព័រកំណត់នេះបាន "នៅក្នុង កាលៈទេសៈពិសេស" តាមសំណើសុំរបស់ភាគីណាមួយ[10]។

៩. ចុងបញ្ចប់ សេចក្តីណែនាំអនុវត្តន៍តម្រូវឲ្យឯកសារនានាដែលត្រូវបានដាក់ជាភាសាខ្មែរ និងជាភាសាមួយផ្សេងទៀត ក៏ប៉ុន្តែចែងថា នៅក្នុង "កាលៈទេសៈពិសេស" អ.ប.ជ អាចនឹងអនុញ្ញាត ឲ្យភាគីដាក់ជាភាសាបារាំង ឬជាភាសាអង់គ្លេសជាមុនបាន ឲ្យតែការបកប្រែជាភាសាខ្មែរនឹងត្រូវ បានដាក់ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន[11]។

## IV. សារណា

១០. ស.ព.អ ស្នើសុំការបន្ថែមទាំងពេលវេលា និងចំនួនទំព័រកំណត់ ដែលបានកំណត់សម្រាប់បណ្តឹង ឧទ្ធរណ៍ ដោយយោងទៅលើកត្តាជាច្រើន ដែលរួមផ្សំបញ្ចូលគ្នាបង្កើតបានជាកាលៈទេសៈ ពិសេស។ ទីមួយ ដើម្បីឲ្យ ស.ព.អ ធ្វើការសម្រេចនានាប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយស្តីពី បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់បាន ដែលដីកាទាំងពីរសុទ្ធតែមាន សេចក្តីសម្រេច និងសំអាងហេតុពាក់ព័ន្ធនឹងអំពីថាតើ យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការរបស់

---

[8] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ.លើកទី៩) ដូចដែលបានពិនិត្យសារឡើងវិញនៅ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន")។

[9] សេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (វិ.លើកទី៨) បានកែប្រែនៅ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ ("សេចក្តីណែនាំអនុវត្តន៍")។

[10] សេចក្តីណែនាំអនុវត្តន៍ មាត្រា ៥.២, ៥.៤។

[11] សេចក្តីណែនាំអនុវត្តន៍ មាត្រា ៧.១, ៧.២។

អ.វ.ត.ក។ ដូចដែល អ.ប.ជ បានកត់សម្គាល់រួចហើយ ទាំងដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានកម្រាស់ក្រាស់ និង ស្មុកស្មាញ និងលើកឡើងនូវបញ្ហាច្បាប់ និងបញ្ហាអង្គហេតុសំខាន់ៗជាច្រើន[12]។

១១. ទីពីរ ការបកប្រែនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ - ដីកាដំណោះស្រាយ ដែល ស.ព.អ មានបំណងប្ដឹងឧទ្ធរណ៍នេះ - ទើបតែមាននៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩ នេះតែប៉ុណ្ណោះ។ ដោយសារតែ ស.ព.អ ធ្វើការតែជាមួយសំណៅជាភាសាអង់គ្លេស វាសំខាន់ណាស់សម្រាប់គាត់ក្នុងការមានពេលវេលាពិនិត្យមើលការបកប្រែនេះដើម្បីធ្វើសេចក្ដីព្រាងបណ្ដឹងឧទ្ធរណ៍របស់គាត់។ ការត្រៀមរៀបចំបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ ក៏នឹងតម្រូវឱ្យមានពេលវេលាបន្ថែមផងដែរ ដោយសារវាត្រូវបានបង្អាក់ដោយសារសំណៅបកប្រែមិនត្រឹមត្រូវបច្ចុប្បន្ននៃឯកសារនេះ។

១២. ជាចុងក្រោយ បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ ពាក់ព័ន្ធនឹងបញ្ហាច្បាប់ និងអង្គហេតុដ៏ស្មុកស្មាញ ដែលជាកត្តាកំណត់ចំពោះអនាគតរបស់សំណុំរឿង០០៤ នេះ ហើយការរៀបចំបណ្ដឹងឧទ្ធរណ៍នេះនឹងទាមទារឱ្យមានពេលវេលា និងធនធានច្រើន។ អង្គជំនុំជម្រះនេះបានសម្រេចពីមុនក្នុងកាលៈទេសៈស្រដៀងគ្នានេះនៅក្នុងសំណុំរឿង០០៤/២ ថាអត្ថិភាពនៃដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងស្មុកស្មាញនេះ និងលទ្ធភាពនៃបណ្ដឹងឧទ្ធរណ៍ខ្វែងគ្នា មានន័យថាចាំបាច់ត្រូវមានពេលវេលានិងចំនួនទំព័របន្ថែម ដើម្បីអនុញ្ញាតឱ្យភាគីនានាធ្វើបណ្ដឹងឧទ្ធរណ៍ប្រដោយប្រសិទ្ធិភាព[13]។

១៣. ក្នុងសំណុំរឿង ០០៤/២ អ.ប.ជ បានអនុញ្ញាតឱ្យគ្រប់ភាគីទាំងអស់ដាក់សារណាបណ្ដឹងឧទ្ធរណ៍រៀងៗខ្លួនរហូតដល់ ១០០ទំព័រ តែមួយភាសា នៅក្នុងរយៈពេល ៤៥ថ្ងៃ (មានន័យថា ១៥ថ្ងៃបន្ថែម) ដោយគិតចាប់ពីពេលជូនដំណឹងនៃសំណៅបកប្រែនៃ ដីកាដំណោះស្រាយទាំងពីរ[14]។ ស.ព.អ គិតថាគាត់នឹងត្រូវការចំនួនសរុប ១០០ ទំព័រ ជាភាសាអង់គ្លេស សម្រាប់បណ្ដឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ និងថា ពេលវេលា

---

[12] ឯកសារ **D381/3** & **D382/3** សេចក្ដីសម្រេចស្ដីពីការបន្ថែម, កថាខណ្ឌ៧។

[13] សំណុំរឿង ០០៤/២-ឯកសារ **D360/7** សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍របស់ [កោសលុប] លើដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សេចក្ដីសម្រេចស្ដីពីការបន្ថែម នៃសំណុំរឿង០០៤/២") កថាខណ្ឌ ៦។

[14] សំណុំរឿង ០០៤/២-ឯកសារ **D360/7** សេចក្ដីសម្រេចស្ដីពីការបន្ថែម នៃសំណុំរឿង០០៤/២, កថាខណ្ឌ ៦ និងផ្នែកសម្រេចសេចក្ដី ៦, ផ្នែកសម្រេចសេចក្ដី។

បន្ថែមចំនួន ៣០ថ្ងៃ នឹងអនុញ្ញាតឲ្យគាត់រៀបចំបណ្តឹងឧទ្ធរណ៍ជាមួយភាសាបាន ដោយមិនបណ្តាលឲ្យមានការពន្យារពេលកិច្ចដំណើរការនីតិវិធីមិនចាំបាច់ឡើយ។ ទោះបីជាមានភាពស្មុគស្មាញស្រដៀងគ្នាក៏ដោយ ក៏ដីកាសម្រេចលើកលែងចោទប្រកាន់នៃសំណុំរឿង០០៤ (៥៥៨ ទំព័រជាភាសាខ្មែរ) គឺវែងជាងដីកាសម្រេចលើកលែងចោទប្រកាន់នៃសំណុំរឿង ០០៤/២ យ៉ាងច្រើន (៤៦១ ទំព័រជាភាសាខ្មែរ)[15] និងគ្របដណ្តប់លើវិសាលភាពអង្គហេតុធំធេងជាង។

១៤. ស.ព.អ នឹងត្រូវការចំនួនទំព័រ និងការបន្ថែមពេលវេលាដែលស្នើសុំនេះ ដើម្បីដោះស្រាយឲ្យបានគ្រប់គ្រាន់នូវបញ្ហានានាដែលបានលើកឡើងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ដ៏ស្មុគស្មាញនេះ។ ការបន្ថែមទាំងនេះនឹងមិនបណ្តាលឲ្យមានការពន្យារពេលកិច្ចដំណើរការនីតិវិធីហួសហេតុនោះឡើយ។

១៥. ស.ព.អ សន្និដ្ឋានថា មូលហេតុដែលបានលើកឡើងខាងលើទាំងនេះ បង្កើតបានជាកាលៈទេសៈពិសេសដើម្បីធានាដល់ការអនុញ្ញាតផ្តល់ជូនការបន្ថែមដែលបានស្នើសុំនេះ ដែលប្រហាក់ប្រហែលគ្នាទៅនឹងការបន្ថែមដែលបានអនុញ្ញាតផ្តល់ជូននៅក្នុងករណីផ្សេងៗទៀត។

## V. ឧបាស្រ័យដែលស្នើឡើង

១៦. អាស្រ័យមូលហេតុដូចបានជម្រាបជូនខាងលើ ស.ព.អ ស្នើសុំ អ.ប.ជ អនុញ្ញាតឲ្យគាត់៖

ក. បន្ថែមពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់គាត់ចំនួន ៣០ថ្ងៃ (ទៅ ៦០ថ្ងៃ) ដល់ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩។

ខ. បន្ថែមចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ចំនួយ ៧០ ទំព័រ ជាភាសាអង់គ្លេស (ទៅ ១០០ទំព័រ)។ និង

[15] សំណុំរឿង ០០៤/២-ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សំណៅជាភាសាខ្មែរ ទំព័រ ៤៦១ (ចប់)។

គ. ដាក់បណ្តឹងឧទ្ធរណ៍នេះជាភាសាអង់គ្លេសតែប៉ុណ្ណោះ ដោយសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់តាមក្រោយឲ្យបានឆាប់ដូចដែលអាចធ្វើទៅបាន៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ | លោក **William SMITH**<br>សហព្រះរាជអាជ្ញាអន្តរជាតិរង<br><br>ជូស<br><br>លោកស្រី **Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ (បម្រុង) | ភ្នំពេញ | |